ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៩៥ អនក្រ.បក

[illegible] យុទ្ធជន
[illegible]
ចូល [illegible] និង [illegible]
លេខ 213 [illegible]
ថ្ងៃទី 22 ខែ 05 ឆ្នាំ 2009
បញ្ជូន

ខុទ្ទកាល័យរដ្ឋមន្ត្រី (ស.វ.យ)
ចូល ថ្ងៃទី 25 ខែ 5 ឆ្នាំ០៩
លេខ 834

# អនុក្រឹត្យ

## ស្តីពី

## របបឧបត្ថម្ភគោលនយោបាយចំពោះមន្ត្រីនគរបាល
## ពលី មរណៈ បន្តស្លាប់ បាត់ខ្លួន និងពិការ

នាយកដ្ឋានសោធននិវត្តន៍យុទ្ធជន
ចូល លេខ: ០៤៥
ថ្ងៃទី២៥ ខែ៥ ឆ្នាំ០៩

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស /៩៤ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម /០១៩៦/០៨ ចុះថ្ងៃទី ២៤ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត ០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិ
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

# សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះកំណត់អំពីរបបឧបត្ថម្ភគោលនយោបាយចំពោះមន្ត្រីនគរបាលជាតិ ដែលបានពលី មរណៈ បង្កស្លាប់ បាត់ខ្លួន និងពិការ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២.-**

វាក្យស័ព្ទដែលប្រើក្នុងអនុក្រឹត្យនេះ មាននិយមន័យដូចតទៅ ÷

- មន្ត្រីនគរបាលពលី សំដៅដល់មន្ត្រីនគរបាលជាតិដែលបាត់បង់ជីវិតនៅពេលដែលបានទទួលបញ្ជាបំពេញបេសកកម្ម ហ្វឹកហាត់មុខជំនាញគ្រោះថ្នាក់បំផុត ធ្វើការពិសោធដ៏មានគ្រោះថ្នាក់ និងដោយសារគ្រោះថ្នាក់ធម្មជាតិក្នុងតំបន់គ្រោះថ្នាក់

- មន្ត្រីនគរបាលមរណៈ សំដៅដល់មន្ត្រីនគរបាលជាតិដែលបំពេញភារកិច្ចក្នុងតំបន់ធម្មតា ហើយត្រូវទទួលគ្រោះថ្នាក់បាត់បង់ជីវិតដោយសារការងារទាំងនោះ ឬដោយសារជំងឺ

- មន្ត្រីនគរបាលបង្កស្លាប់ សំដៅដល់មន្ត្រីនគរបាលជាតិដែលបានបាត់បង់ជីវិតដោយធ្វើអត្តឃាត ឬដោយសារបង្កគ្រោះថ្នាក់ដល់បាត់បង់ជីវិតដោយផ្ទាល់ ឬដោយប្រយោលដែលល្មើសច្បាប់ វិន័យ និងបទបញ្ជា

- មន្ត្រីនគរបាលបាត់ខ្លួន សំដៅដល់មន្ត្រីនគរបាលជាតិដែលបានទទួលបញ្ជាបំពេញបេសកកម្មហ្វឹកហាត់មុខជំនាញឯកទេស និងធ្វើការពិសោធប្រកបដោយគ្រោះថ្នាក់ ហើយត្រូវបាត់ខ្លួនដែលពុំអាចសន្និដ្ឋានបានថាស្លាប់ ឬរស់ រត់ចោលជួរ ឬត្រូវជនល្មើសចាប់

- មន្ត្រីនគរបាលពិការ សំដៅដល់មន្ត្រីនគរបាលជាតិដែលបាត់បង់សរីរាង្គណាមួយ ឬច្រើននៅលើរាងកាយ ក្នុងពេលដែលបានទទួលបញ្ជាបំពេញបេសកកម្មហ្វឹកហាត់មុខជំនាញគ្រោះថ្នាក់បំផុត ធ្វើការពិសោធដ៏មានគ្រោះថ្នាក់ និងដោយសារគ្រោះថ្នាក់ធម្មជាតិក្នុងតំបន់គ្រោះថ្នាក់ ឬក្នុងពេលបំពេញការងារធម្មតា ។

## ជំពូកទី ២
## ប្រភេទមន្ត្រីនគរបាលពិការ

**មាត្រា ៣.-**

មន្ត្រីនគរបាលពិការមាន២ប្រភេទគឺ ÷

១- មន្ត្រីនគរបាលពិការប្រភេទ "ក" ជាមន្ត្រីនគរបាលជាតិដែលមានជំងឺរបួសក្នុងពេលទទួលបញ្ជាបំពេញបេសកកម្មហ៊ឹកហាត់មុខជំនាញគ្រោះថ្នាក់បំផុត ធ្វើការពិសោធដ៏មានគ្រោះថ្នាក់ និងដោយសារគ្រោះថ្នាក់ធម្មជាតិក្នុងតំបន់គ្រោះថ្នាក់ ត្រូវបានចែកចេញជា ៤ថ្នាក់ ÷

- ថ្នាក់ទី១ មានកំរិតបាត់បង់សមត្ថភាពការងារលើសពី ៨០ ( ប៉ែតសិប ) ភាគរយ
- ថ្នាក់ទី២ មានកំរិតបាត់បង់សមត្ថភាពការងារលើសពី ៦០ ( ហុកសិប ) ភាគរយ
- ថ្នាក់ទី៣ មានកំរិតបាត់បង់សមត្ថភាពការងារលើសពី ៤០ ( សែសិប ) ភាគរយ
- ថ្នាក់ទី៤ មានកំរិតបាត់បង់សមត្ថភាពការងារលើសពី ២០ ( ម្ភៃ ) ភាគរយ

២- មន្ត្រីនគរបាលពិការប្រភេទ "ខ" ជាមន្ត្រីនគរបាលជាតិដែលមានជំងឺរបួសក្នុងពេលបំពេញការងារធម្មតា ត្រូវបានចែកចេញជា ៣ថ្នាក់ ÷

- ថ្នាក់ទី១ មានកំរិតបាត់បង់សមត្ថភាពការងារលើសពី ៨០ ( ប៉ែតសិប ) ភាគរយ
- ថ្នាក់ទី២ មានកំរិតបាត់បង់សមត្ថភាពការងារលើសពី ៦០ ( ហុកសិប ) ភាគរយ
- ថ្នាក់ទី៣ មានកំរិតបាត់បង់សមត្ថភាពការងារលើសពី ៤០ ( សែសិប ) ភាគរយ។

**មាត្រា ៤.-**

មន្ត្រីនគរបាលពិការប្រភេទ "ក" នៅពេលទទួលមរណៈភាព ត្រូវបានទទួលស្គាល់ជាមន្ត្រីនគរបាលពលី ។

មន្ត្រីនគរបាលពិការប្រភេទ "ក" នៅពេលរងរបួសបន្ថែមទៀតដោយសារទទួលបញ្ជាបំពេញបេសកកម្ម ឬបំពេញការងារធម្មតា ត្រូវបានពិនិត្យវាយតម្លៃថ្នាក់ពិការឡើងវិញ។

**មាត្រា ៥.-**

មន្ត្រីនគរបាលពិការប្រភេទ "ខ" នៅពេលទទួលមរណៈភាព ត្រូវបានទទួលស្គាល់ជាមន្ត្រីនគរបាលមរណៈ។

មន្ត្រីនគរបាលពិការប្រភេទ "ខ" នៅពេលរងរបួសបន្ថែមទៀតដោយសារបំពេញបេសកកម្ម ត្រូវបានទទួលស្គាល់ជាមន្ត្រីនគរបាលពិការប្រភេទ "ក" វិញ។

មាត្រា ៦.-

ការវាយតម្លៃប្រភេទថ្នាក់ពិការ ត្រូវធ្វើឡើងដោយក្រុមប្រឹក្សាវាយតម្លៃមួយរបស់ក្រសួងមហាផ្ទៃ ដោយផ្អែកតាមប្រកាសអន្តរក្រសួងរវាងក្រសួងមហាផ្ទៃ ក្រសួងសុខាភិបាល និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

## ជំពូកទី ៣
## របបឧបត្ថម្ភចំពោះមន្ត្រីនគរបាលពលី មរណៈ បាត់ខ្លួន និងពិការ

មាត្រា ៧.-

មន្ត្រីនគរបាលពលីត្រូវបានទទួលប្រាក់ឧបត្ថម្ភដូចខាងក្រោម ÷

- ប្រាក់ឧបត្ថម្ភស្មើនឹងទឹកប្រាក់ចំនួន ៩ (ប្រាំបួន)ខែ នៃប្រាក់បៀវត្សរ៍សរុបប្រចាំខែចុងក្រោយរបស់មន្ត្រីនគរបាលពលី ជូនដល់គ្រួសារសព ឬអង្គភាពដែលទទួលបន្ទុករៀបចំធ្វើបុណ្យបូជា ឬបញ្ចុះសព

- ប្រាក់ឧបត្ថម្ភមួយលើកដំបូងជូនគ្រួសារសព ស្មើនឹងទឹកប្រាក់ចំនួន ១៥ (ដប់ប្រាំ)ខែ នៃប្រាក់បៀវត្សរ៍សរុបប្រចាំខែចុងក្រោយរបស់មន្ត្រីនគរបាលពលី

- ប្រាក់ឧបត្ថម្ភជំនួយគ្រួសារជាប្រចាំខែជូនដល់ប្រពន្ធ ឬប្តី កូនបង្កើត ឪពុកម្តាយបង្កើត ឬអ្នកអាណាព្យាបាលរបស់មន្ត្រីនគរបាលពលី តាមប្រកាសអន្តរក្រសួងរវាងក្រសួងមហាផ្ទៃ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយមានការឯកភាពពីរាជរដ្ឋាភិបាល។

មាត្រា ៨.-

មន្ត្រីនគរបាលមរណៈត្រូវបានទទួលប្រាក់ឧបត្ថម្ភដូចខាងក្រោម ÷

- ប្រាក់ឧបត្ថម្ភស្មើនឹងទឹកប្រាក់ចំនួន ៧ (ប្រាំពីរ) ខែ នៃប្រាក់បៀវត្សរ៍សរុបប្រចាំខែចុងក្រោយរបស់មន្ត្រីនគរបាលមរណៈជូនដល់គ្រួសារសព ឬអង្គភាពដែលទទួលបន្ទុករៀបចំធ្វើបុណ្យបូជា ឬបញ្ចុះសព

- ប្រាក់ឧបត្ថម្ភមួយលើកដំបូងជូនគ្រួសារសពស្មើនឹងទឹកប្រាក់ចំនួន ១២ (ដប់ពីរ)ខែ នៃប្រាក់បៀវត្សរ៍សរុបប្រចាំខែចុងក្រោយរបស់មន្ត្រីនគរបាលមរណៈ

- ប្រាក់ឧបត្ថម្ភជំនួយគ្រួសារជាប្រចាំខែជូនដល់ប្រពន្ធ ឬប្តី កូនបង្កើត ឪពុកម្តាយបង្កើត ឬអ្នកអាណាព្យាបាលរបស់មន្ត្រីនគរបាលមរណៈតាមប្រកាសអន្តរក្រសួងរវាងក្រសួងមហាផ្ទៃ ក្រសួងសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយមានការឯកភាពពីរាជរដ្ឋាភិបាល។

**មាត្រា ៩.-**

មន្ត្រីនគរបាលបង្កស្លាប់ត្រូវបានទទួលប្រាក់ឧបត្ថម្ភដូចខាងក្រោម ៖

- ប្រាក់ឧបត្ថម្ភស្មើនឹងទឹកប្រាក់ចំនួន ៥ (ប្រាំ) ខែ នៃប្រាក់បៀវត្សរ៍សរុបប្រចាំខែចុងក្រោយរបស់មន្ត្រីនគរបាលបង្កស្លាប់ជូនដល់គ្រួសារសព ឬអង្គភាពដែលទទួលបន្ទុករៀបចំធ្វើបុណ្យបូជា ឬបញ្ចុះសព

- ប្រាក់ឧបត្ថម្ភមួយលើកផ្ដាច់ជូនដល់គ្រួសារសពស្មើនឹងទឹកប្រាក់ចំនួន ១២(ដប់ពីរ) ខែ នៃប្រាក់បៀវត្សរ៍សរុបប្រចាំខែចុងក្រោយរបស់មន្ត្រីនគរបាលបង្កស្លាប់ ។

**មាត្រា ១០.-**

មន្ត្រីនគរបាលបាត់ខ្លួនត្រូវបានទទួលប្រាក់ឧបត្ថម្ភដូចខាងក្រោម ៖

- បន្តបើកប្រាក់បៀវត្សរ៍របស់មន្ត្រីនគរបាលបាត់ខ្លួនព្រមទាំងរបបអង្គរប្រចាំខែជូនគ្រួសារ ចាប់ពីខែឆ្នាំបាត់ខ្លួនរហូតដល់គំរប់ ១២ (ដប់ពីរ ) ខែ

- ក្រោយ ១២ (ដប់ពីរ )ខែ គិតចាប់ពីខែឆ្នាំបាត់ខ្លួនមកនៅតែពុំឃើញវិលត្រឡប់មកវិញ ត្រូវបានកំណត់ទទួលស្គាល់ជាមន្ត្រីនគរបាលពលី ហើយគ្រួសារត្រូវបានទទួលប្រាក់ឧបត្ថម្ភដូចជាមន្ត្រីនគរបាលពលីដែរ លើកលែងតែប្រាក់ឧបត្ថម្ភសំរាប់បូជា ឬបញ្ចុះសព

- ក្នុងអំឡុងពេលកំពុងទទួលប្រាក់ឧបត្ថម្ភណាមួយក្នុងចំណុចទាំងពីរខាងលើ ប្រសិនបើមន្ត្រីនគរបាលបាត់ខ្លួនបានវិលត្រឡប់មកអង្គភាពដើម ឬវិលទៅលំនៅដ្ឋានវិញ ការផ្ដល់ប្រាក់ឧបត្ថម្ភត្រូវតែបញ្ឈប់ចាប់ពីខែឆ្នាំដែលមន្ត្រីនគរបាលបាត់ខ្លួននោះមានមុខ ។ ក្នុងករណីបានទទួលស្គាល់ជាមន្ត្រីនគរបាលពលីដោយបានកាត់ផ្ដាច់ក្របខ័ណ្ឌចេញពីក្រសួងមហាផ្ទៃរួចហើយ ស្រាប់តែមន្ត្រីនគរបាលបាត់ខ្លួននោះបានវិលត្រឡប់មកវិញ ហើយចង់ចូលបំរើការងារបន្តទៀត ត្រូវបានបញ្ចូលក្របខណ្ឌជាថ្មីដោយទទួលឋានន្តរសក្តិ និងប្រាក់បៀវត្សរ៍ដូចមុនពេលបាត់ខ្លួន ។

**មាត្រា ១១.-**

ជនដែលមានគ្រប់លក្ខណៈសម្បត្តិអាចទទួលរបបឧបត្ថម្ភរបស់មន្ត្រីនគរបាលពលី មរណៈ បង្កស្លាប់ និងបាត់ខ្លួនរួមមាន ៖

- ឪពុក និងម្ដាយបង្កើត ឬអ្នកអាណាព្យាបាលតាំងពីវ័យកុមាររបស់មន្ត្រីនគរបាលជាតិ បើសិនជាមន្ត្រីនគរបាលនោះនៅលីវ

- ប្រពន្ធ ឬប្ដីរបស់មន្ត្រីនគរបាលជាតិដែលមានលិខិតអាពាហ៍ពិពាហ៍ ហើយពុំទាន់រៀបអាពាហ៍ពិពាហ៍ជាថ្មីទៀត

- កូនបង្កើតរបស់មន្ត្រីនគរបាលជាតិដែលមានសំបុត្រកំណើតអាយុក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំចុះ និងមានអាយុ ១៨ ( ដប់ប្រាំបី ) ឆ្នាំឡើង ដែលមានលិខិតបញ្ជាក់កំពុងបន្តការសិក្សាហើយពុំមានទទួលអាហារូបករណ៍ ឬកូនដែលពិការភាពមានលិខិតបញ្ជាក់ត្រឹមត្រូវ

- ឪពុកម្ដាយបង្កើត ឬអ្នកអាណាព្យាបាលដែលមានកូនពលី ឬមរណៈចំនួន ២ (ពីរ ) នាក់ ឡើងទៅ ត្រូវបានទទួលរបបឧបត្ថម្ភគុណតាមចំនួនកូនដែលបានពលី ឬមរណៈនោះ ។

មាត្រា ១២.-

ប្រាក់ឧបត្ថម្ភចំពោះមន្ត្រីនគរបាលពិការប្រភេទ "ក" មានដូចខាងក្រោម ÷

១-ក្រោយពេលព្យាបាលជំងឺរបួសជាសះស្បើយ ហើយត្រូវបានទទួលប្រាក់ឧបត្ថម្ភបំប៉នសុខភាព នៅមជ្ឈមណ្ឌលបំប៉នសុខភាពតាមរយៈពេលកំណត់ និងតាមលំដាប់ថ្នាក់ពិការ ដូចខាងក្រោម ÷

- ថ្នាក់ទី១ ត្រូវបានអនុញ្ញាតអោយឈប់សម្រាករយៈពេល ៩០ (កៅសិប) ថ្ងៃ
- ថ្នាក់ទី២ ត្រូវបានអនុញ្ញាតអោយឈប់សម្រាករយៈពេល ៦០ (ហុកសិប) ថ្ងៃ
- ថ្នាក់ទី៣ ត្រូវបានអនុញ្ញាតអោយឈប់សម្រាករយៈពេល ៤៥ (សែសិបប្រាំ) ថ្ងៃ
- ថ្នាក់ទី៤ ត្រូវបានអនុញ្ញាតអោយឈប់សម្រាករយៈពេល ៣០ (សាមសិប) ថ្ងៃ ។

២- មន្ត្រីនគរបាលពិការដែលនៅបន្តការងារក្នុងក្របខណ្ឌមន្ត្រីនគរបាលជាតិ ត្រូវបានទទួលប្រាក់ឧបត្ថម្ភជំនួយមុខរបួសជាប្រចាំខែ ដោយគិតសមាមាត្រភាគរយនៃប្រាក់បៀវត្សរ៍សរុបប្រចាំខែផ្ទាល់ខ្លួន និងតាមលំដាប់ថ្នាក់ពិការដូចខាងក្រោម ÷

- ថ្នាក់ទី១ ត្រូវបានទទួលប្រាក់របបឧបត្ថម្ភស្មើនឹង ៤៥ (សែសិបប្រាំ) ភាគរយ
- ថ្នាក់ទី២ ត្រូវបានទទួលប្រាក់របបឧបត្ថម្ភស្មើនឹង ៤០ (សែសិប) ភាគរយ
- ថ្នាក់ទី៣ ត្រូវបានទទួលប្រាក់របបឧបត្ថម្ភស្មើនឹង ៣៥ (សាមសិបប្រាំ) ភាគរយ
- ថ្នាក់ទី៤ ត្រូវបានទទួលប្រាក់របបឧបត្ថម្ភស្មើនឹង ៣០ (សាមសិប) ភាគរយ ។

៣- មន្ត្រីនគរបាលពិការដែលក្រសួងមហាផ្ទៃសម្រេចអោយចេញពីក្របខណ្ឌមន្ត្រីនគរបាលជាតិ ត្រូវបានទទួលប្រាក់ឧបត្ថម្ភអតីតភាពបំរើការងារមិនលើសពី ២៤ (ម្ភៃបួន) ខែ ដោយគិតតាមរយៈពេលបំរើការងារក្នុងក្របខណ្ឌមន្ត្រីនគរបាលជាតិក្នុង ១ (មួយ) ឆ្នាំ ត្រូវបានទទួលប្រាក់ឧបត្ថម្ភអតីតភាពចំនួន ២ (ពីរ) ខែ ។ ចំពោះមន្ត្រីនគរបាលពិការដែលបំរើការងារក្នុងក្របខណ្ឌមន្ត្រីនគរបាលជាតិមិនទាន់គ្រប់រយៈពេល ១ (មួយ) ឆ្នាំ ហើយពិការ ក៏ត្រូវបានទទួលប្រាក់ឧបត្ថម្ភអតីតភាពចំនួន ២ (ពីរ) ខែ ដែរ។

៤- មន្ត្រីនគរបាលពិការត្រូវបានទទួលប្រាក់ឧបត្ថម្ភមួយលើកដំបូង តាមលំដាប់ថ្នាក់ពិការដូចខាងក្រោម ÷

- ថ្នាក់ទី១ ត្រូវបានទទួលប្រាក់ឧបត្ថម្ភស្មើនឹងទឹកប្រាក់ចំនួន ១២ (ដប់ពីរ) ខែ នៃប្រាក់បៀវត្សរ៍សរុបប្រចាំខែចុងក្រោយរបស់មន្ត្រីនគរបាលពិការ
- ថ្នាក់ទី២ ត្រូវបានទទួលប្រាក់ឧបត្ថម្ភស្មើនឹងទឹកប្រាក់ចំនួន ១០ (ដប់) ខែ នៃប្រាក់បៀវត្សរ៍សរុបប្រចាំខែចុងក្រោយរបស់មន្ត្រីនគរបាលពិការ
- ថ្នាក់ទី៣ ត្រូវបានទទួលប្រាក់ឧបត្ថម្ភស្មើនឹងទឹកប្រាក់ចំនួន ៨ (ប្រាំបី) ខែ នៃប្រាក់បៀវត្សរ៍សរុបប្រចាំខែចុងក្រោយរបស់មន្ត្រីនគរបាលពិការ
- ថ្នាក់ទី៤ ត្រូវបានទទួលប្រាក់ឧបត្ថម្ភស្មើនឹងទឹកប្រាក់ចំនួន ៦ (ប្រាំមួយ) ខែ

នៃប្រាក់បៀវត្សរ៍សរុបប្រចាំខែចុងក្រោយរបស់មន្ត្រីនគរបាលពិការ ។

៥- ត្រូវបានបន្តបើកប្រាក់បៀវត្សរ៍សរុបប្រចាំខែ ដោយគិតតាមឋានន្តរសក្តិចុងក្រោយមុនពេលសម្រេចអោយចេញពីក្របខណ្ឌមន្ត្រីនគរបាលជាតិ និងចំនួនកូននៅក្នុងបន្ទុកជាក់ស្តែងរបស់នគរបាលពិការ ។

៦- មន្ត្រីនគរបាលពិការដែលរស់នៅក្នុងមណ្ឌលជនពិការ និងមន្ត្រីនគរបាលពិការដែលផ្ទេរចេញពីក្របខណ្ឌមន្ត្រីនគរបាលជាតិ ត្រូវបានទទួលប្រាក់ឧបត្ថម្ភជំនួយមុខរបួសជាប្រចាំខែដោយគិតសមាមាត្រ ភាគរយនៃប្រាក់បៀវត្សរ៍សរុបប្រចាំខែផ្ទាល់ខ្លួន និងតាមលំដាប់ថ្នាក់ពិការដូចខាងក្រោម ÷

-ថ្នាក់ទី១ត្រូវបានទទួលប្រាក់របបឧបត្ថម្ភជំនួយមុខរបួសស្មើនឹង ១០០ (មួយរយ) ភាគរយ

- ថ្នាក់ទី២ ត្រូវបានទទួលប្រាក់របបឧបត្ថម្ភជំនួយមុខរបួសស្មើនឹង ៨០(ប៉ែតសិប ) ភាគរយ

- ថ្នាក់ទី៣ ត្រូវបានទទួលប្រាក់របបឧបត្ថម្ភជំនួយមុខរបួសស្មើនឹង ៦០(ហុកសិប ) ភាគរយ

- ថ្នាក់ទី៤ ត្រូវបានទទួលប្រាក់របបឧបត្ថម្ភជំនួយមុខរបួសស្មើនឹង ៤០(សែសិប) ភាគរយ ។

៧- មន្ត្រីនគរបាលពិការថ្នាក់ទី១ ត្រូវបានទទួលរបបឧបត្ថម្ភអ្នកបំរើផ្ទាល់ខ្លួន ១នាក់ ជាប្រចាំខែរហូតដល់មន្ត្រីនគរបាលពិការនោះស្លាប់ ដែលមានទឹកប្រាក់ស្មើនឹងប្រាក់បៀវត្សរ៍សរុបអប្បបរមាផ្ទាល់ខ្លួនរបស់មន្ត្រីនគរបាលជាតិដែលមានឋានន្តរសក្តិពលបាលត្រី ។

៨- ត្រូវបានទទួលរបបឧបត្ថម្ភចិញ្ចឹមប្រពន្ធ ឬប្តី កូន ដូចពេលកំពុងបំរើការងារដែរ ។

**មាត្រា ១៣ ._**

ប្រាក់ឧបត្ថម្ភចំពោះមន្ត្រីនគរបាលពិការប្រភេទ "ខ" មានដូចខាងក្រោម ÷

១- មន្ត្រីនគរបាលពិការដែលក្រសួងមហាផ្ទៃសម្រេចអោយចេញពីក្របខណ្ឌមន្ត្រីនគរបាលជាតិ ត្រូវបានទទួលប្រាក់ឧបត្ថម្ភអតីតភាពបំរើការងារមិនលើសពី ៨ (ប្រាំបី) ខែ ដោយគិតតាមរយៈពេលបំរើការងារក្នុងក្របខណ្ឌមន្ត្រីនគរបាលជាតិក្នុង ១ (មួយ ) ឆ្នាំ ត្រូវបានទទួលប្រាក់ឧបត្ថម្ភអតីតភាពចំនួន ២ (ពីរ) ខែ ។ ចំពោះមន្ត្រីនគរបាលពិការដែលបំរើការងារក្នុងក្របខណ្ឌមន្ត្រីនគរបាលជាតិមិនទាន់គ្រប់រយៈពេល ១ (មួយ) ឆ្នាំ ហើយពិការ ក៏ត្រូវបានទទួលប្រាក់ឧបត្ថម្ភអតីតភាពចំនួន ២ខែ (ពីរខែ) ដែរ ។

២- ត្រូវបានទទួលប្រាក់ឧបត្ថម្ភជាប្រចាំខែ ដោយគិតសមាមាត្រភាគរយនៃប្រាក់បៀវត្សរ៍សរុប ចុងក្រោយផ្ទាល់ខ្លួន និងតាមលំដាប់ថ្នាក់ពិការដូចខាងក្រោម ÷

-ថ្នាក់ទី១ ត្រូវបានទទួលប្រាក់របបឧបត្ថម្ភស្មើនឹង ៩០ (កៅសិប ) ភាគរយ

-ថ្នាក់ទី២ ត្រូវបានទទួលប្រាក់របបឧបត្ថម្ភស្មើនឹង ៨០ (ប៉ែតសិប ) ភាគរយ

- ថ្នាក់ទី៣ ត្រូវបានទទួលប្រាក់របបឧបត្ថម្ភស្មើនឹង ៧០ ( ចិតសិប ) ភាគរយ ។

៣- ត្រូវបានទទួលរបបឧបត្ថម្ភចិញ្ចឹមប្រពន្ធ ឬប្តី កូន ដូចពេលកំពុងបំរើការងារដែរ ។

មាត្រា ១៤ .-

មន្ត្រីនគរបាលពិការទាំងពីរប្រភេទគ្រប់លំដាប់ថ្នាក់ ត្រូវបានទទួលប្រាក់ឧបត្ថម្ភបន្ថែម ដូចខាងក្រោម ÷

១- រាល់ថ្ងៃបុណ្យចូលឆ្នាំខ្មែរ បុណ្យភ្ជុំបិណ្ឌ និងថ្ងៃបុណ្យរំលឹកគុណមន្ត្រីនគរបាលពលី ពិការ ( កំណត់យកថ្ងៃបុណ្យភ្ជុំបិណ្ឌ ) ត្រូវបានទទួលប្រាក់ឧបត្ថម្ភដូចមន្ត្រីរាជការដែលកំពុងបំរើការងារដែរ ។

២-ពេលមានជំងឺរបួស ឬពេលរបួសសើរើត្រូវបានទទួលការសង្គ្រោះព្យាបាលរហូតជាសះស្បើយ នៅតាមមន្ទីរពេទ្យរដ្ឋដោយឥតគិតថ្លៃ ។

៣- ត្រូវបានរដ្ឋជួយស្តារលទ្ធភាពពលកម្ម កាយសម្បទា និងផ្តល់ឧបករណ៍ទ្រទ្រង់រាងកាយ ដោយឥតបង់ប្រាក់ ជួយបណ្តុះបណ្តាលមុខវិជ្ជាជីវៈ និងត្រូវបានជួយបង្កអោយមានមុខរបរសមស្រប តាមសមត្ថភាព និងលទ្ធភាពជាក់ស្តែងរបស់មន្ត្រីនគរបាលពិការ ។

៤- ចំពោះមន្ត្រីនគរបាលពិការជាស្ត្រី ត្រូវបានទទួលឧបត្ថម្ភបន្ថែមនូវការធានារ៉ាប់រងសង្គម ដូចស្ត្រីដែលកំពុងបំរើការងារមន្ត្រីរាជការដែរ ។

៥-មន្ត្រីនគរបាលពិការដែលនៅបំរើការងារ ពេលគ្រប់លក្ខណៈសម្បត្តិចូលនិវត្តន៍ត្រូវបាន ទទួលប្រាក់សោធននិវត្តន៍ តាមច្បាប់កំណត់ដោយមានរួមបញ្ចូលទាំងប្រាក់ឧបត្ថម្ភជំនួយមុខរបួសជា ប្រចាំខែដូចពេលកំពុងបំរើការងារដែរ ។

## ជំពូកទី ៤
## ការទទួលខុសត្រូវលើប្រាក់ឧបត្ថម្ភចំពោះមន្ត្រីនគរបាលពលី មរណៈ បង្កស្លាប់ បាត់ខ្លួន និងពិការ

មាត្រា ១៥ .-

ក្រសួងមហាផ្ទៃជាអ្នកទទួលបន្ទុកដោះស្រាយនូវរាល់ការចំណាយដូចខាងក្រោម :

- ប្រាក់ឧបត្ថម្ភសំរាប់បូជា ឬបញ្ចុះសព

- ប្រាក់ឧបត្ថម្ភជូនគ្រួសារមន្ត្រីនគរបាលពលី មរណៈ និងបង្កស្លាប់មួយលើកដំបូង

-ប្រាក់ឧបត្ថម្ភជំនួយមុខរបួសដល់មន្ត្រីនគរបាលពិការនៅបំរើការងារក្នុងក្របខណ្ឌ មន្ត្រីនគរបាលជាតិ

-ប្រាក់ឧបត្ថម្ភបំប៉នសុខភាពមន្ត្រីនគរបាលពិការ